ពេលយើងតាមព្រះយេស៊ូវ ទ្រង់នឹងនាំយើងលើសពី.....

When we follow Jesus, he will lead us beyond....

ម៉ាកុស Mark 7:24-37

២៤ ទ្រង់ក្រោកឡើងយាងចេញពីទីនោះ ទៅឯប្រទល់ដែនស្រុកទីរ៉ុស និងស្រុកស៊ីដូន រួចចូលទៅក្នុងផ្ទះ១ មិនចង់ឲ្យអ្នកណាដឹងសោះ តែទ្រង់នៅកំបាំងពុំបាន ២៥ ដ្បិតមានស្ត្រីម្នាក់មានកូនស្រី១ ដែលអារក្សអសោចចូល នាងបានឮនិយាយពីទ្រង់ ក៏មកទំលាក់ខ្លួនក្រាបនៅទៀបព្រះបាទទ្រង់ ២៦ (រីឯស្ត្រីនោះ ជាសាសន៍ក្រេក កូនកាត់ស៊ីរ៉ូ-ភេនីស) នាងក៏ទូលអង្វរឲ្យទ្រង់ដេញអារក្សពីកូនស្រីនាងចេញ ២៧ តែព្រះយេស៊ូវមានព្រះបន្ទូលទៅនាងថា ទុកឲ្យកូនក្មេងស៊ីឆ្អែតជាមុនសិន ព្រោះមិនគួរនឹងយកនំប៉័ងរបស់កូនក្មេងបោះទៅឲ្យឆ្កែស៊ីនេ ២៨ នាងទូលឆ្លើយថា ម៉ែនហើយ ព្រះអម្ចាស់ ប៉ុន្តែឆ្កែនៅក្រោមតុក៏ស៊ីកំទេចពីកូនក្មេងដែរ ២៩ នោះទ្រង់មានព្រះបន្ទូលថា ដោយព្រោះពាក្យនោះ ចូរនាងទៅចុះ អារក្សបានចេញពីកូននាងហើយ ៣០ រួចកាលនាងបានទៅដល់ផ្ទះវិញ ក៏ឃើញកូនដេកនៅលើគ្រែ អារក្សបានចេញស្រេចហើយ។ ៣១ លំដាប់ពីនោះមក ទ្រង់ចេញពីព្រំដែនស្រុក

ទីរ៉ុស និងស៊ីដូន ក៏យាងកាត់ស្រុកដេកាប៉ូល មកដល់សមុទ្រកាលីឡេវិញ ៣២ នោះមានគេនាំមនុស្សថ្លង់ម្នាក់ ដែលនិយាយទាំងពិបាកមកឯទ្រង់ ក៏ទូលអង្វរឲ្យទ្រង់ដាក់ព្រះហស្តលើគាត់ ៣៣ ទ្រង់ក៏នាំគាត់ចេញពីហ្វូងមនុស្សទៅដោយឡែក យកអង្គុលីព្រះហស្តដាក់ក្នុងត្រចៀកគាត់ រួចស្តោះទឹកព្រះឱស្ឋ ហើយពាល់អណ្តាតគាត់ ៣៤ កាលទ្រង់បានងើបព្រះនេត្រទៅលើមេឃហើយ នោះទ្រង់ថ្ងូរ រួចមានព្រះបន្ទូលទៅគាត់ថា «អេប៉ាថា» គឺថា ឲ្យបើកឡើង ៣៥ ស្រាប់តែត្រចៀកក៏បើក សរសៃអណ្តាតបានធូរ នោះគាត់និយាយបានយ៉ាងច្បាស់ ៣៦ ទ្រង់ហាមមិនឲ្យគេប្រាប់ឲ្យអ្នកណាដឹងឡើយ ប៉ុន្តែដែលទ្រង់ហាមប៉ុណ្ណា នោះគេចេះតែប្រកាសប្រាប់រឹតតែច្រើនឡើងប៉ុណ្ណោះទៀត ៣៧ គេនឹកប្លែកក្នុងចិត្តជាខ្លាំងពន់ពេក ដោយ

ពាក្យថា លោកបានធ្វើការទាំងអស់សុទ្ធតែល្អ គឺបានប្រោសទាំងមនុស្សថ្លង់ឲ្យស្តាប់ឮ ហើយមនុស្សគអឲ្យនិយាយបាន។

១- ជួបប្រទះជាមួយស្ត្រីសាសន៍ដទៃ (7:24-30)

Encounter With a Non-Jewish Woman

២- ជួបប្រទះជាមួយបុរសសាសន៍ដទៃ (7:31-37)

Encounter with a Non-Jewish Man